ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៦៥/១១-សាហាន់**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន សាហាន់ អ៊ិនធើណេសិនណល (ខេមបូឌា)**

អាសយដ្ឋាន : ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៤៩៤ ៥៦៩ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក Kim Jae Dong | ប្រធានក្រុមហ៊ុន |
| ២- លោក យៀវ រដ្ឋា | ប្រធានរដ្ឋបាល |
| ៣- លោក ប៉ែន សុធា | មន្ត្រីច្បាប់ |

២- ភាគីកម្មករនិយោជិត

ក/ឈ្មោះ : - **សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ**

- **សហជីពសម្លេងយុវជនខ្មែរ ក្រុមហ៊ុន សា ហាន់**

អាសយដ្ឋាន : ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣-៨៨១-៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23-881-824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

លេខទូរស័ព្ទ : ០១២ ៧១៣ ០៦៥ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក អន សាខន អគ្គលេខាធិការសហព័ន្ធសហជីពសម្លេងយុជនខ្មែរ

២- លោក អុល សំអាត មន្ត្រីសហព័ន្ធសហជីពសម្លេងយុជនខ្មែរ

៣- លោក កោះ សុឃា ប្រធានសហជីពសម្លេងយុជនខ្មែរ ក្រុហ៊ុន សា ហាន់

ខ/ឈ្មោះ : **- សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ**

**- សហជីពស្ត្រីកម្ពុជា ក្រុមហ៊ុន សា ហាន់**

អាសយដ្ឋាន : ភូមិត្រពាំងថ្នឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៧១៣ ០៦៥ ទូរសារ : គ្មាន

១- លោក សន ចំរើន ប្រធានសហជីពស្ត្រីកម្ពុជា ក្រុមហ៊ុន សា ហាន់

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ប្រធានក្រុមទីមួយ១ នៅតែទាមទារមិនឱ្យក្រុមហ៊ុនកាត់ប្រាក់លើកទឹកចិត្ត នៅពេលដេរមិនបានគ្រប់ចំនួនតាមការកំណត់របស់រោងចក្រ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុននៅតែរក្សាឱ្យប្រធានក្រុមទីមួយ១ដេរគ្រប់ចំនួនតាមការកំណត់ដដែល ទើបក្រុមហ៊ុនផ្តល់ប្រាក់លើកទឹកចិត្តជូនបាន។

២- លោក នាង សុធារ៉ា ជាលេខាធិការសហជីពស្ត្រីកម្ពុជានៅតែទាមទាឱ្យក្រុមហ៊ុនទទួលយករូបលោកចូលធ្វើការជាធម្មតាវិញ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចទទួលយកលោក នាង សុធារ៉ា ឱ្យចូលធ្វើការវិញបានទេ ហើយក្រុមហ៊ុនក៏មិនបានដឹងថា លោក នាង សុធារ៉ា ជាលេខាធិការសហជីពស្ត្រីកម្ពុជាឡើយ ហើយនៅពេលដែលក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារ ដោយមិនបានជូនដំណឹងទៅសាមីខ្លួន និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៥៨២ ក.ប/អក/វ.ក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ ។

**សវនាការ និង សន្ទេបនីតិវិធី**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ (វេលាម៉ោង ២:០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ លេខ ៦៤១/១១ សសសយខ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០២ ចំណុច លើការទាមទារចំនួន ០៩ ចំណុច ។ ចំណុចមិនសះជាចំនួន ០២ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៥៨២ កប/អក/វក. ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០២ ចំណុចនេះ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ វេលាម៉ោង ០២:០០ នាទី រសៀល ។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០២ ចំណុចនេះ បន្ថែមទៀត ប៉ុន្តែពុំបានទទួលការសះជានឹងគ្នាទេ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរក ឃើញនៃអង្គហេតុ ដូចខាងក្រោម ។

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- របាយការណ៍ដើមហេតុនៃវិវាទទាំង ២ ចំណុច ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១។

២- លក្ខន្តិកៈក្រុមហ៊ុន សាហាន់ អ៊ិនធើណេសិនណល (ខេមបូឌា) ចុះបញ្ជិកាលេខ ៥៤៥៣ ល.ប ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០០៨។

៣- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន សាហាន់ អ៊ិនធើណេសិនណល (ខេមបូឌា) ចុះបញ្ជិកាលេខ ៧៧ កប/អក/អធក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១០។

៤- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន សាហាន់ អ៊ិនធើណេសិនណល (ខេមបូឌា) លេខ ០៧២៩ ពណ.ទតក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨។

៥- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពស្ត្រីកម្ពុជា ក្រុមហ៊ុន សាហាន់ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១។

៦- លិខិតជូនដំណឹងបញ្ចប់កិច្ចសន្យា, ពាក្យសុំចូលបំរើការងារ, កិច្ចសន្យាការងារសាកល្បង, អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, សំបុត្រកំណើត, កិច្ចសន្យាមានថិរវេលាកំណត់របស់ឈ្មោះ នាង សុធារ៉ា។

៧- តារាងប្រាក់ឈ្នួល សម្រាប់អ្នកលាលែងពីការងារ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១។

៨- តារាងប្រាក់ឈ្នួលសម្រាប់ប្រធានក្រុម ៣៨ ពីថ្ងៃទី០១ ខែមីនា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- លិខិតរបស់សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីសំណើរសុំលោកប្រធានមេត្តាជួយអន្តរាគមន៍ និងដោះស្រាយនូវករណីវិវាទរបស់កម្មករនិយោជិត ក្រុមហ៊ុន សាហាន់ លេខ ៦៤១/១១ ស.ស.ស.យ.ខ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១១។

២- លិខិតរបស់កម្មករ-កម្មការនីបំរើការនៅរោងចក្រ សាហាន់ គោរពចូលមកលោកអគ្គនាយក គ្រប់គ្រងទូទៅសហព័ន្ធសហជីពសម្លេងយុវជនខ្មែរ ស្តីពីសុំឱ្យលោកអគ្គនាយកមេត្តាជួយអន្តរាគមន៍ និងដោះស្រាយនូវសំណូមពរលក្ខខណ្ឌការងារ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១។

៣- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពសម្លេងយុវជនខ្មែរ ក្រុមហ៊ុន សាហាន់ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០។

៤- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពស្ត្រីកម្ពុជា ក្រុមហ៊ុន សាហាន់ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ:**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន សាហាន់ លេខ ៥៨២ ក.ប/អក/វ.ក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន សាហាន់ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៣៧៤ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៣៧៥ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ៣៩៥ កប/អក/វក/លកអ. ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១១។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ៣៩៦ កប/អក/វក/លកអ. ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន សាហាន់ គឺជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់។ ក្រុមហ៊ុននេះ ចាប់ផ្តើមដំណើរការដំបូងក្នុងឆ្នាំ ២០០៨។ ក្រុមហ៊ុននេះ ជួលកម្មករនិយោជិតចំនួនប្រហែលជា ១ ១០០ នាក់។
- សហជីពសម្លេងយុវជនខ្មែរ និងសហជីពស្ត្រីកម្ពុជា គឺជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។
- សហជីពសម្លេងយុវជនខ្មែរក្រុមហ៊ុន សាហាន់ បានចុះបញ្ជិកាសហជីព នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០។ ហើយសហជីពស្ត្រីកម្ពុជា ក្រុមហ៊ុន សាហាន់ ចុះបញ្ជិកាសហជីព នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១។
- សហជីពសម្លេងយុវជនខ្មែរមានសមាជិកចំនួន៣០០នាក់។ សហជីពស្ត្រីកម្ពុជាមានសមាជិកចំនួន ៤០ នាក់។

**ចំណុចវិវាទទី១: កម្មករនិយោជិត ទាមទារឱ្យនិយោជក កុំឱ្យកាត់រង្វាន់លើកទឹកចិត្តនៅពេលដេរមិនបានគ្រប់ចំនួនតាមការកំណត់របស់រោងចក្រ**

- នៅក្នុងឆ្នាំ២០១០ ក្រុមហ៊ុនបានកំណត់ប្រាក់រង្វាន់ជូនដល់ប្រធានក្រុមទាំងឡាយចំនួន ៣០ ដុល្លារអាមេរិក ក្នុងមួយខែ។ លក្ខខណ្ឌក្នុងការផ្តល់ជូនប្រាក់រង្វាន់នេះ គឺប្រធានក្រុមត្រូវដឹកនាំកូនក្រុមរបស់ខ្លួន ឱ្យដេរតាមផែនការ ដែលនិយោជកបានដាក់ជូន ហើយប្រធានក្រុមទាំងអស់បានដឹងពីគោលការណ៍នេះរួចហើយ។

- មានប្រធានក្រុមចំនួន ៣ នាក់ ដែលដឹកនាំកូនក្រុមរបស់ខ្លួនឱ្យដេរពុំបានតាមការកំណត់របស់និយោជក នៅក្នុងខែមិនា ឆ្នាំ២០១១។ ហេតុដូច្នេះ និយោជកពុំបានផ្តល់ប្រាក់រង្វាន់ជូនដល់ប្រធានក្រុមទាំង ៣ នាក់ នេះទេ។
- តាមរយៈសារណា ដែលផ្តល់ដោយភាគីនិយោជក ប្រធានក្រុមទាំង ៣ នាក់ នោះមានឈ្មោះ ណុំ ណារី អត្តលេខ ១៩២៩ ជាប្រធានក្រុមដេរទី១២. ឈ្មោះ សេង ស្រីនាង អត្តលេខ ៦៣៨១ ប្រធានក្រុមដេរទី១១. និងឈ្មោះ អុតត ចាន់ដារ៉ា អត្តលេខ ៣៨៤៦ ជាប្រធានក្រុមដេរទី១១។ ប្រធានក្រុមទាំង ៣ នេះទទួលបានប្រាក់ឈ្នួលគោលចំនួន ៨០ ដុល្លារអាមេរិក ក្នុងមួយខែ។
- នៅក្នុងក្រុមហ៊ុន មានក្រុមដេរទាំងអស់ចំនួន ១៨ ក្រុម។ នៅក្នុងក្រុមនីមួយៗ មានកម្មករនិយោជិត ចំនួនប្រហែលជា ៣៨ ទៅ ៤៤ នាក់។ ជាទូទៅ កម្មករនិយោជិតដេរទៅតាមការកំណត់ម៉ូតរបស់និយោជក។
- ភាគីនិយោជកបានលើកឡើងថា នៅក្នុងខែមីនា ឆ្នាំ២០១១ នេះ និយោជកបានកំណត់ឱ្យកម្មករនិយោជិតដេរចំនួន ២០០០ ទៅ ៣០០០ ដុំ ក្នុងមួយថ្ងៃ។ ប៉ុន្តែប្រធានក្រុមដេរ ចំនួន ៣ នាក់ ខាងលើនោះ ពុំអាចដឹកនាំកូនក្រុមរបស់ខ្លួនដេរបានតាមការកំណត់ទេ ពោលគឺបានចំនួនតែ ៩០០ ទៅ ១២០០ ដុំ ក្នុងមួយថ្ងៃប៉ុណ្ណោះ។ ចំណែកឯក្រុមដ៏ទៃទៀត គឺពួកគាត់ដេរបានតាមការកំណត់របស់ក្រុមហ៊ុន។ ភាគីនិយោជកបានបញ្ជាក់បន្ថែមទៀតថា ប្រាក់រង្វាន់សម្រាប់ប្រធានក្រុមនេះ គឺជាប្រាក់លើកទឹកចិត្តដល់កម្មករនិយោជិត ឱ្យខិតខំប្រឹងប្រែងធ្វើការ។ វាមិនមែនជាប្រាក់ឈ្នួលទេ ហើយប្រធានក្រុមនិមួយៗក៏បានដឹងពីព័ត៌មាននេះដែរ។
- ប្រធានក្រុមទាំង ៣ នាក់ នោះ ពុំមានវត្តមាន នៅក្នុងសវនាការ។ ហើយភាគីកម្មករនិយោជិត ដែលតំណាងឱ្យប្រធានក្រុមទាំង ៣ នាក់ ខាងលើ ក៏ពុំបានដឹងពីព័ត៌មានលំអិតទាក់ទងទៅនឹងមូលហេតុ ដែលពុំទទួលបានប្រាក់រង្វាន់នេះដែរ។ ភាគីកម្មករនិយោជិតគ្រាន់តែបញ្ជាក់ថា អាចបណ្តាលមកពីកូនក្រុម ឧស្សាហ៍ឈប់ខ្វះកំលាំងកម្មករនិយោជិត ហើយបើមានកម្មករនិយោជិតថ្មីមកដេរជំនួស ក៏ពួកគាត់ដេរយឺតដែរ។
- ក្នុងករណីនេះ ភាគីនិយោជកបានបដិសេធទាំងស្រុងថា នៅក្នុងក្រុមដេរនិមួយៗបើមានកម្មករនិយោជិតឈប់នោះ និយោជកនឹងចាត់ចែងឱ្យមានកំលាំងកម្មករនិយោជិត ដែលចេះជំនាញនេះ មកជួយដេរជំនួសតែម្តង ពោលពុំឱ្យមានបញ្ហារាំងស្ទះទេ។
- ភាគីកម្មករនិយោជិតបានលើកឡើងពីមូលហេតុនៃការទាមទារនេះថា យោងតាមមាត្រា ១០២ នៃច្បាប់ស្តីពីការងារបានចែងថា ប្រាក់រង្វាន់លើកទឹកចិត្ត ក៏ជាចំណែកនៃប្រាក់ឈ្នួលដែរ ហើយបើយោងតាមមាត្រា ២៨ នៃច្បាប់ស្តីពីការងារ គឺបានហាមឃាត់ពុំឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតទេ។ ក្នុងករណីនេះ និយោជកពុំអាចកាត់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន៣០ ដុល្លារអាមេរិករបស់កម្មករនិយោជិតទេ។

**ចំណុចវិវាទទី២: កម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកលោក នាង សុធារ៉ា ដែលជាលេខាធិការសហជីពចូលធ្វើការវិញ**

- កម្មករ នាង សុធារ៉ា ចូលធ្វើការនៅដំបូងនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១០ ដោយមានកិច្ចសន្យាការងារសាកល្បងចំនួន ៣ ខែ។ បន្ទាប់មកនិយោជក បានបន្តជូនគាត់រយៈពេល ៣ ខែ បន្តទៀត ដោយគិតចាប់ពីថ្ងៃទី ១២ ខែមករា ដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១។
- នៅពេលបញ្ចប់កិច្ចសន្យាចុងក្រោយនេះ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ និយោជកបានជូនដំណឹងស្តីពីការមិនបន្តកិច្ចសន្យានេះ។ មូលហេតុដោយសារកម្មករ នាង សុធារ៉ា ឧស្សាហ៍ចេញដើរទៅកន្លែងផ្សេងៗជាដែកពុំយកចិត្តទុកដាក់នឹងការងារ ហើយម្យ៉ាងទៀត ក្រុមហ៊ុនពុំសូវមានការងារធ្វើទៀត ដូចនេះ និយោជកក៏សម្រេចមិនបន្តកិច្ចសន្យាការងារថ្មីជូនគាត់តែម្តងទៅ។
- នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១ កម្មករ នាង សុធារ៉ា បានទទួលប្រាក់ឈ្នួល និងប្រាក់បញ្ចប់កិច្ចសន្យាការងាររួចហើយ។
- ភាគីកម្មករនិយោជិតបានលើកឡើងថា ការទាមទារនេះ គឺដោយសារតែគាត់មានតួនាទីជាលេខាធិការសហជីព។ តាមឯកសាររបស់កម្មករនិយោជិតបានបង្ហាញថា កម្មករ នាង សុធារ៉ា មានតួនាទីជាលេខាធិការសហជីពស្ត្រីកម្ពុជាប្រចាំក្រុមហ៊ុន សាហាន់។ កាលបរិច្ឆេទទទួលបានបញ្ជិកា គឺនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១។
- ភាគីនិយោជកបានលើកឡើងថា កន្លងមកនិយោជក ពុំដែលដឹងថា កម្មករ នាង សុធារ៉ា ជាលេខាធិការសហជីពទេ សូម្បីតែលិខិតជូនដំណឹងស្តីពីការបោះឆ្នោតសហជីពក៏មិនបានបញ្ជាក់ដែរ។ ពោលគឺទើបតែដឹងនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ ដែលនិយោជកបានទទួលលិខិតជូនដំណឹងថា កម្មករ នាង សុធារ៉ា មានតួនាទីជាលេខាធិការសហជីពស្ត្រីកម្ពុជា។
- នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតទាមទារឱ្យទទួលយកកម្មករ នាង សុធារ៉ា ចូលធ្វើការវិញព្រមទាំងសងប្រាក់រំលឹក ចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ ដោយផ្អែកលើមាត្រា ២៩២. មាត្រា ២៩៣ និង មាត្រា ២៩៤ នៃច្បាប់ស្តីពីការងារ។
- នៅថ្ងៃសវនាការ តំណាងសហជីពបានលើកឡើងថា ខ្លួនបានជូនដំណឹងទៅក្រុមហ៊ុនរួចហើយ អំពីកាលបរិច្ឆេទបោះឆ្នោតសហជីព។ ប៉ុន្តែភាគីសហជីពស្ត្រីកម្ពុជាខ្លួនឯងផ្ទាល់ ពុំបានដឹងពីកាលបរិច្ឆេទនៃការបោះឆ្នោតនេះទេ ហើយក៏ពុំបានដឹងថា តើមានកម្មករនិយោជិតចំនួនប៉ុន្មាននាក់បានចូលរួមបោះឆ្នោត. ហើយពួកគាត់ទទួលបានការគាំទ្រសន្លឹកឆ្នោតប៉ុន្មានដែរ។ ទន្ទឹមនឹងនេះដែរ ចំពោះទីតាំងនៃការបោះឆ្នោត ក៏ពួកគាត់ពុំបានដឹងដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យភាគីសហជីពស្ត្រីកម្ពុជាផ្តល់ឯកសារទាំងនេះ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែក្រុមប្រឹក្សាអាជ្ញាកណ្តាលពុំបានទទួលព័ត៌មានលំអិតទាំងនោះពីសហជីពទេ។

- ភាគីនិយោជកបានអះអាង និងបង្ហាញភស្តុតាងថា កម្មករ នាង សុធារ៉ា បានយល់ព្រមទទួលយកប្រាក់ឈ្នួលបញ្ចប់កិច្ចសន្យាពីក្រុមហ៊ុន ហើយក៏យល់ព្រមឈប់ទាមទារចូលធ្វើការវិញដែរ។ ក្នុងករណីនេះ ភាគីតំណាងសហជីពពុំបានដឹងពីព័ត៌មាននេះទេ។ នៅក្នុងសវនាការដែរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យភាគីតំណាងសហជីពបញ្ជាក់ជាមួយសាមីខ្លួនម្តងទៀត ដើម្បីបញ្ជាក់ឱ្យច្បាស់ថា ខ្លួនឈប់ទាមទារចូលធ្វើការវិញឬទៅ? ភាគីតំណាងសហជីពបានព្យាយាមទាក់ទងទៅដែរ ប៉ុន្តែពុំអាចទាក់ទងកម្មករ នាង សុធារ៉ា បានទេរហូតដល់ថ្ងៃចេញសេចក្តីបង្គាប់នេះ។

## ហេតុផលនៃសេចក្តីសម្រេចៈ

**ចំណុចវិវាទទី១: កម្មករនិយោជិតទាមទារនិយោជកកុំឱ្យកាត់រង្វាន់លើកទឹកចិត្តនៅពេលដេរមិនបានគ្រប់ចំនួនតាមការកំណត់របស់រោងចក្រ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងពិចារណាដូចខាងក្រោមនេះ:

មាត្រា ២ នៃច្បាប់ស្តីពីការងារចែងថា *"........នឹងទុកជានិយោជកដែលបង្កើតសហគ្រាស តាមន័យនៃច្បាប់នេះ លុះត្រាតែបុគ្គលទាំងនោះមានប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះមិនបានជាប់លាប់ក៏ដោយ។ -សហគ្រាស............។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំនៃនិយោជក "*។

ផ្អែកលើខ្លឹមសារនៃមាត្រា២ខាងលើនេះ នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា *"និយោជកមានសិទ្ធិ និង អំណាចគ្រប់គ្រង និង ដឹកនាំធនធានមនុស្សនៅក្នុងក្រុមហ៊ុន ដរាបណាការគ្រប់គ្រងនេះ ធ្វើឡើងទៅតាមច្បាប់ និងសមហេតុសមផល"។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១១៦/០៧-ប្រ៊្លេស សាន់ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២)*។

នៅក្នុងសំណុំរឿងលេខ ៨១/០៨-គ្លូបល អាប៉ារ៉ែល ចំណុចវិវាទទី៤ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សិទ្ធិនៅក្នុងការចាត់ចែង និងដឹកនាំរបស់ក្រុមហ៊ុននេះ ក៏រួមបញ្ចូលនូវសិទ្ធិក្នុងការកំណត់នូវប្រាក់រង្វាន់លើកទឹកចិត្តដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅតាមក្រុមអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនខាងលើដែរ។

ក្នុងករណីនេះ និយោជកពុំបានផ្តល់ជូនប្រាក់រង្វាន់ចំនួន ៣០ ដុល្លារអាមេរិក នៅក្នុងខែមីនា ឆ្នាំ២០១១ ដល់ប្រធានក្រុមចំនួន ៣ នាក់ ទេ ដោយសំអាងថា ពួកគាត់ទាំង ៣ នាក់ ពុំបានដឹកនាំកូនក្រុមដេរបានតាមការកំណត់របស់និយោជក។ ភាគីកម្មករនិយោជិតពុំបានបញ្ជាក់ពីមូលហេតុ ដែលបណ្តាលឱ្យពួកគាត់ពុំទទួលបានប្រាក់រង្វាន់ចំនួន៣០ ដុល្លារអាមេរិកក្នុងមួយខែនេះ ក្រៅពីលើកយកមាត្រា ២៨ និងមាត្រា ១០២ នៃច្បាប់ស្តីពីការងារដែលបានចែងថា ប្រាក់រង្វាន់លើកទឹកចិត្តក៏ជាចំណែកនៃប្រាក់ឈ្នួលដែរ ហើយបើយោងតាមមាត្រា ២៨ នៃច្បាប់

ស្តីពីការងារ គឺបានហាមឃាត់ពុំឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតទេ។

មាត្រា២៨ នៃច្បាប់ស្តីពីការងារចែងថា *"និយោជកមិនត្រូវធ្វើការពិន័យជាប្រាក់ ឬដាក់ទោសវិន័យទ្វេមួយជាពីរចំពោះកំហុសដដែល១តែមួយ។ ការពិន័យជាប្រាក់មានន័យថា វិធានការទាំងឡាយដែលនាំឱ្យមានការកាត់បន្ថយប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែលត្រូវទទួលបានជាធម្មតាដោយការបំពេញការងារនេះ"*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ប្រាក់ឈ្នួលគោលរបស់ប្រធានក្រុមទាំង ៣ នេះ ទទួលបាន ៨០ ដុល្លារអាមេរិក។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការមិនផ្តល់ជូនប្រាក់រង្វាន់លើកទឹកចិត្តនៅពេលដែលប្រធានក្រុមធ្វើមិនដល់គោលដៅ ដែលនិយោជកកំណត់នោះ មិនមែនជាការពិន័យជាប្រាក់ដើម្បីកាត់បន្ថយប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែលត្រូវទទួលបានជាធម្មតាដោយការបំពេញការងារនោះទេ ពីព្រោះប្រាក់លើកទឹកចិត្តចំនួន ៣០ ដុល្លារអាមេរិកនេះ មិនមែនជាប្រាក់ដែលកម្មករនិយោជិតត្រូវទទួលបានជារៀងរាល់ខែទេ។ ប្រាក់រង្វាន់លើកទឹកចិត្តនេះ គឺជាប្រាក់សម្រាប់លើកទឹកចិត្តដល់ប្រធានក្រុម ដែលបានដឹកនាំកូនក្រុមរបស់ខ្លួនឱ្យធ្វើបានដល់គោលដៅ ដែលកំណត់ដោយក្រុមហ៊ុន។ នៅពេលដែលប្រធានក្រុមធ្វើមិនដល់គោលដៅ ដែលបានកំណត់នេះ ពួកគាត់មិនទទួលបានប្រាក់នេះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២៨ នៃច្បាប់ស្តីពីការងារមិនអាចយកមកអនុវត្តបានទេ នៅក្នុងករណីនេះ។

មាត្រា ១០២ និងមាត្រា ១០៣ នៃច្បាប់ស្តីពីការងារបានកំណត់អំពីនិយមន័យនៃប្រាក់ឈ្នួល និងភាគនៃប្រាក់ឈ្នួល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ថ្វីត្បិតតែប្រាក់រង្វាន់ជាផ្នែកមួយនៃប្រាក់ឈ្នួល ក៏ពិតមែន ប៉ុន្តែសិទ្ធិក្នុងការទទួលប្រាក់រង្វាន់ គឺមិនដូចគ្នាទៅនឹងសិទ្ធិទទួលបានប្រាក់ឈ្នួលទេ។ ប្រាក់ឈ្នួល គឺជាប្រាក់ដែលកម្មករនិយោជិតត្រូវទទួលនូវពេលដែលពួកគាត់បានបំពេញការងារទៅតាមកិច្ចសន្យា។ ចំណែកឯប្រាក់រង្វាន់វិញ គឺជាប្រាក់បន្ថែម ដែលត្រូវបានផ្តល់ជូនសម្រាប់ជាការលើកទឹកចិត្ត ដោយមានភ្ជាប់នូវលក្ខខណ្ឌអ្វីមួយ។ នៅក្នុងកិច្ចសន្យាការងារ ជាទូទៅភាគីនិយោជកមានសិទ្ធិចាត់ចែងជាអ្នកកំណត់ល័ក្ខខ័ណ្ឌ និងចំនួនកំណត់ណាមួយ ហើយក៏ជាអ្នកផ្តល់ជូននូវប្រាក់រង្វាន់នេះដែរ ប៉ុន្តែត្រូវធានាឱ្យបានថា លក្ខខណ្ឌដែលកំណត់នេះ ត្រូវមានលក្ខណៈសមរម្យ និងមិនក្រោមច្បាប់កំណត់ទេ។ ចំណែកឯភាគីកម្មករនិយោជិត គឺជាអ្នកខិតខំបំពេញតាមលក្ខខណ្ឌនោះ ដើម្បីទទួលប្រាក់រង្វាន់។ ជាទូទៅ ភាគីដែលត្រូវទទួលបានប្រាក់រង្វាន់ លុះត្រាតែភាគីនោះបានបំពេញនូវលក្ខខណ្ឌជាក់លាក់ ឬតាមការកំណត់ណាមួយរបស់ភាគីម្ខាងទៀត គឺនិយោជក។ ជាគោលការណ៍ សម្រាប់ការអនុវត្តក្នុងការផ្តល់ជូនប្រាក់រង្វាន់ បើភាគីមួយដែលជាកម្មករនិយោជិតមិនអាចបំពេញតាមការកំណត់របស់ភាគីម្ខាងទៀតទេ កម្មករនិយោជិតនោះនឹងមិនមានសិទ្ធិទទួលបានប្រាក់រង្វាន់នេះទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នៅពេលដែលប្រធានក្រុមទាំង ៣ មិនបានដឹកនាំកូនក្រុមរបស់ពួកគាត់ឱ្យធ្វើការងារដល់គោលដៅនោះ ពួកគាត់ពុំមានសិទ្ធិទទួលបាននូវប្រាក់រង្វាន់ចំនួន ៣០ ដុល្លារអាមេរិក សម្រាប់ខែមីនា ឆ្នាំ២០១១ ទេ។

សរុបសេចក្តីទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធការទាមទារឱ្យនិយោជកសងប្រាក់រង្វាន់លើកទឹកចិត្ត ចំនួន ៣០ ដុល្លារអាមេរិក នៅក្នុងខែមីនា ជូនដល់ប្រធានក្រុមទាំង ៣ នាក់ ដែលមានឈ្មោះ ណុំ ណារី ប្រធានក្រុមដេរទី១២ ឈ្មោះ សេង ស្រីនាង ប្រធានក្រុមដេរទី១១ និងឈ្មោះ អុតត ចាន់ដារ៉ា ប្រធានក្រុម ដេរទី១១។

**ចំណុចវិវាទទី២: កម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកកម្មករ នាង សុធារ៉ា ដែលជាលេខាធិការសហជីពចូលធ្វើការវិញ**

ភាគីកម្មករនិយោជិតបានទាមទារឱ្យទទួលយកកម្មករ នាង សុធារ៉ា ចូលធ្វើការវិញព្រមទាំងសងប្រាក់រំលឹកចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ ដោយផ្អែកលើមាត្រា ២៩២. មាត្រា ២៩៣ និងមាត្រា ២៩៤។

នៅក្នុងករណីនេះ ក្រោយពេលបញ្ចប់កិច្ចសន្យាការងារសាកល្បង និយោជកបានបន្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាជូនកម្មករ នាង សុធារ៉ា ចំនួន ៣ ខែបន្តទៀត ដោយគិតចាប់ពីថ្ងៃទី១២ ខែមករា ដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១។

មាត្រា ៧៣ កថាខ័ណ្ឌ នៃច្បាប់ស្តីពីការងារបានចែងថា *"ប្រសិនបើកិច្ចសន្យាមានកំណត់ថិរវេលា លើសពីប្រាំមួយខែ កម្មករនិយោជិតត្រូវបានគេជូនដំណឹងជាមុន ចំនួនដប់ថ្ងៃអំពីការផុតរលត់នៃកិច្ចសន្យា ឬការមិនបន្តឡើងវិញនៃកិច្ចសន្យា។ រយៈពេលជូនដំណឹងមុននេះ ត្រូវកំណត់ឱ្យដល់ដប់ប្រាំថ្ងៃចំពោះកិច្ចសន្យា ដែលមានថិរវេលាលើសពីមួយឆ្នាំ។ បើគ្មានការជូនដំណឹងមុនទេ កិច្ចសន្យាត្រូវបន្តក្នុងថិរវេលាស្មើគ្នានឹងថិរវេលា ដែលបានចុះកិច្ចសន្យាគ្រាដំបូង ឬត្រូវចាត់ទុកថា ជាកិច្ចសន្យាគ្មានកំណត់ថិរវេលាពិតប្រាកដ បើថិរវេលាសរុបនៃការបន្តកិច្ចសន្យានោះ លើសពីថិរវេលាដែលមានកំណត់ក្នុងមាត្រា ៦៧ "*។

យោងតាមមាត្រាខាងលើ ការជូនដំណឹង គឺតម្រូវឱ្យមាននៅពេលដែលកិច្ចសន្យាការងាររបស់កម្មករនិយោជិតលើសពី ៦ ខែ។ តាមអង្គហេតុ កិច្ចសន្យាការងាររបស់កម្មករ នាង សុធារ៉ា គឺមានរយៈពេល ៣ ខែប៉ុណ្ណោះ ហេតុនេះ ការជូនដំណឹងនៃការមិនបន្តកិច្ចសន្យាការងាររបស់និយោជក គឺមានលក្ខណៈល្អប្រសើរជាងច្បាប់ ។

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិតលើកឡើងថា កម្មករ នាង សុធារ៉ា ជាលេខាធិការសហជីព ហើយការទាមទារនេះ គឺផ្អែកលើមាត្រា ២៩២. មាត្រា ២៩៣ និងមាត្រា ២៩៤ នៃច្បាប់ស្តីពីការងារ។

មាត្រា ២៩២ នៃច្បាប់ស្តីពីការងារចែងថា *" ការបោះឆ្នោតជាភារកិច្ចរបស់និយោជក។ ក្នុងករណីដែលមិនទាន់មានប្រតិភូបុគ្គលិក និយោជកត្រូវតែកំណត់ថ្ងៃបោះឆ្នោត..."* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទនៅក្នុងសំណុំរឿងនេះ មិនទាក់ទងនឹងការបោះឆ្នោតរបស់ប្រតិភូបុគ្គលិកទេ។ ដូចនេះ មាត្រា ២៩២ ខាងលើនេះ មិនអាចយកមកអនុវត្តបានទេ។

មាត្រា ២៩៣ នៃច្បាប់ស្តីពីការងារចែងថា *" រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជន*

*ណាម្នាក់ពីការងាររបស់ខ្លួនអាចធ្វើបាន លុះត្រាណាតែមានការយល់ព្រមពីអធិការការងារ..."។*

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា *"មាត្រា ២៩៣ នៃច្បាប់ស្តីពីការងារមិនអាចយកមកអនុវត្តលើករណីនៃការផុតរលត់កិច្ចសន្យាបានទេ ព្រោះថា មាត្រានេះបានចែងយ៉ាងច្បាស់អំពីការការពារ ប្រឆាំងនឹងការបញ្ឈប់ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីពពីការងាររបស់និយោជក និងមិនបានរាប់បញ្ចូលអំពីស្ថានភាពដែលកិច្ចសន្យាការងារផុតរលត់ "។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៣៤/០៥-ហ្សាក់ស៊ីនតិច លេខ ១០/០៩- ញូ វ៉ាយដី ហេតុផលចំណុចវិវាទទី១ និង ទី២ និងលេខ ០៥/១១-អ៊ីម វ៉ៃ ១ ហេតុផលចំណុចវិវាទទី៥)។*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា ទង្វើនេះជាការបញ្ចប់កិច្ចសន្យាការងារតាមកាលបរិច្ឆេទផុតរលត់នៃកិច្ចសន្យា និងការមិនបន្តកិច្ចសន្យាសារជាថ្មីទៀត ប៉ុន្តែនេះមិនមែនជាការបញ្ឈប់កម្មករពីការងារនោះទេ ដោយហេតុថា ការបញ្ឈប់មានន័យថា និយោជកផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតក្នុងអំឡុងពេល ដែលកិច្ចសន្យាកំពុងអនុវត្ត ហើយមិនទាន់ដល់កាលផុតកំណត់នៃកិច្ចសន្យា។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា មាត្រា ២៩៣ នៃច្បាប់ស្តីពីការងារ មិនអាចយកមកអនុវត្តបានទេនៅក្នុងអង្គហេតុខាងនេះ ហើយនិយោជកមិនមានកាតព្វកិច្ចត្រូវសុំការអនុញ្ញាតពីអធិការការងារ ដើម្បីមិនបន្តកិច្ចសន្យាការងាររបស់កម្មករ នាង សុធារ៉ា នោះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការមិនបន្តកិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលារបស់កម្មករ នាង សុធារ៉ា នេះ មិនមានអ្វីខុសនឹងច្បាប់ទេ។

ម្យ៉ាងវិញទៀត នៅក្នុងសវនាការ ភាគីនិយោជកបានអះអាង និងបង្ហាញភស្តុតាងថា កម្មករ នាង សុធារ៉ា បានយល់ព្រមទទួលយកប្រាក់បញ្ចប់កិច្ចសន្យាការងារពីក្រុមហ៊ុន ហើយយល់ព្រមឈប់ទាមទារឱ្យទទួលយកធ្វើការវិញហើយ។ ក្នុងករណីនេះ សហជីពដែលបានតំណាងកម្មករ នាង សុធារ៉ា ក្នុងការនាំដំណើងមកនោះ ពុំបានដឹងពីព័ត៌មាននេះទេ។ នៅក្នុងសវនាការដែរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យភាគីតំណាងសហជីពបញ្ជាក់ជាមួយសាមីខ្លួនម្តងទៀត ដើម្បីបញ្ជាក់ឱ្យច្បាស់ថា ខ្លួនឈប់ទាមទារចូលធ្វើការវិញឬទេ? ភាគីតំណាងសហជីពបានព្យាយាមទាក់ទងទៅដែរ ប៉ុន្តែពុំអាចទាក់ទងសាមីខ្លួនបានទេ រហូតដល់ថ្ងៃចេញសេចក្តីបង្គាប់នេះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករ នាង សុធារ៉ា អាចបោះបង់ការទាមទារចូលធ្វើការវិញ ដោយសារទី១ គាត់មិនបានមកចូលរួមក្នុងសវនាការ និងទី២ គាត់បានទទួលប្រាក់ផ្សេងៗពីក្រុមហ៊ុនរួចទៅហើយ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកទទួលយកកម្មករ នាង សុធារ៉ា ចូលធ្វើការវិញ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ :

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១:**

បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកសងប្រាក់រង្វាន់លើកទឹកចិត្ត ចំនួន ៣០ ដុល្លារអាមេរិក នៅក្នុងខែមីនា ជូនដល់ប្រធានក្រុមទាំង ៣ នាក់ ដែលមានឈ្មោះ ណុំ ណារី ប្រធានក្រុមដេរទី ១២ ឈ្មោះ សេង ស្រីនាង ប្រធានក្រុមដេរទី១១ និងឈ្មោះ អុត ចាន់ដារ៉ា ប្រធានក្រុមដេរទី១១។

**ចំណុចវិវាទទី២:**

បដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជក ទទួលយក កម្មករ នាង សុធារ៉ា ចូលធ្វើការវិញ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **អ៊ឹង សុន្ធី**

ហត្ថលេខា: ------------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **នួន ស៊ីផាន់**

ហត្ថលេខា: ------------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **ម៉ែន ម៉ុនឈរា**

ហត្ថលេខា: ------------------------------------

THE ARBITRATION COUNCIL